# សាសនាក្នុងអរិយធម៌មេសូប៉ូតាមី

ការលេចឡើងនូវជំនឿសាសនានៅក្នុងប្រវត្តិសាស្ត្រមនុស្ស គឺជាប្រធានបទមួយដែលមានការជជែកគ្នាយ៉ាងច្រើនក្នុងចំណោមអ្នកស្រាវជ្រាវមួយចំនួនដូចជា ប្រវត្តិវិទូ, នរវិទូ និងបុរាណវិទូជាដើម។ យើងអាចដឹងអំពីសាសនា និងការគោរពរបស់មនុស្សសម័យបុរាណគឺតាមរយៈភស្តុតាងបុរាណវិទ្យា និងការគោរពប្រចាំថ្ងៃរបស់មនុស្សបច្ចុប្បន្ន ដែលភស្តុតាងបុរាណវិទ្យានោះរួមមាន ដូចជា ស្ថានីយបញ្ចុះសព , សិលាចារឹក, សំណង់ស្ថាបត្យកម្ម និងវត្ថុសិល្បៈផ្សេងៗ។

ភស្តុតាងដំបូងដែលបានបង្ហាញ អំពីការគោរពសាសនាក្នុងអរិយធម៌មេសូប៉ូតាមីនោះគឺការបង្ហាញតាមរយៈការកសាងប្រាសាទ ការឆ្លាក់រូបមនុស្ស មនុស្សមានក្បាលជាសត្វ និង សត្វ។ ការឆ្លាក់នោះនៅមានតាមជញ្ជាំង លើផ្ទាំងសិលាចារឹកដែលចារជាអក្សរ Cuneiform និងសសរនៅតាមប្រាសាទដែលបានបង្ហាញអំពីការជឿ និងការគោរពទៅលើអាទិទេព។ ជាមួយគ្នានោះដែរការកសាងប្រាសាទគឺកើតឡើងតាមរយៈទស្សនៈនៃសាសនាដែលមនុស្សក្នុងអរិយធម៌នេះជឿលើអាទិទេពគ្រប់គ្រង និងការពារចក្រវាល។ រាល់ទីក្រុងនៃអរិយធម៌មេសូប៉ូតាមី សុទ្ធសឹងតែមានការកសាងប្រាសាទ Ziggurat ដើម្បីឧទ្ទិសដល់អាទិទេពផ្សេងៗដែលមានន័យថាទីក្រុងទាំងនោះ គឺបានភ្ជាប់ជានឹងអាទិទេពតាមរយៈ Ziggurat។[១] Ziggurat គឺជាប្រាសាទដែលមានរាងខឿនខ្ពស់ មានជណ្តើរនៅខាងមុខ និងនៅខាងលើមានប្រាសាទតូចមួយ។ ឧទាហរណ៍៖ ប្រាសាទដែលល្បីល្បាញមួយក្នុងអរិយធម៌នេះ គឺមានឈ្មោះ Ziggurat of Ur ឬ White Temple ដែលបច្ចុប្បន្នស្ថិតនៅក្នុងប្រទេសអ៊ីរ៉ាក់ ដែលសម្រាប់ឧទ្ទិសដល់អាទិទេពមួយដែលមានឈ្មោះថា Anu ( Sky god) ដែលស្ថិតក្នុងសម័យកាល Sumer (រូបលេខ១)។[២] នៅក្នុងសម័យកាល Babylon ប្រាសាទ Ziggurat គឺ

---

[១] www.worldhsitory.org:Mesopotamia Religion

[២] Barbette Stanley Spaeth 2013:34

កសាងសម្រាប់ឧទ្ទិសដល់អាទិទេព Marduk ដែលជាអាទិទេពបង្កើតទឹក រុក្ខជាតិ និងជាទេពនៃសម្រាប់ យុតិធម៌ ដែលអាទិទេព Marduk នេះជាទេពដែលក្នុងសម័យ Babylon និយមគោរព។[៣]

សាសនានៅក្នុងអរិយធម៌មេសូប៉ូតាមីគឺមនុស្សជឿទៅលើអាទិទេពថា ដែលពួកគេជឿថា អាទិទេពជាអ្នកបង្កើតភពផែនដី រួមទាំងមនុស្ស សត្វ និងរុក្ខជាតិផងដែរ[៤] ហើយអាទិទេពទាំងនោះមានទំនាក់ទំនងជាមួយនឹងប្រព័ន្ធតារានិករ។[៥] អាទិទេពទាំងអស់នោះប្រៀបបានដូចនឹង ជា Hero សម្រាប់ការពារ សង្គ្រោះ ព្យាបាល មនុស្សលោក ហើយស្តេចគឺជាអ្នកដែលមានទំនាក់ទំនងជាមួយនឹងអាទិទេព (រូបលេខ៣)។[៦] នៅពេលដែលមហាក្សត្រសុគតគេនាំគ្នាកសាងជារូបសំណាកស្តេច ដែលប្រដូចនឹងអាទិទេព សម្រាប់ការពារប្រជាជនពីសភាវៈអាក្រក់ផ្សេងៗ (រូបលេខ៤)។[៧]

អាទិទេពដែលមានអំណាច និងសំខាន់ៗជាងគេនៅក្នុងអរិយធម៌មេសូមប៉ូតាមីហៅថា អាទិទេពទាំង ប្រាំពីរ[៨] ដែលមានដូចជា Enlil ជាទេពគ្រប់គ្រង ទឹកដី ភ្លើង ខ្យល់ និងជាទេពធំជាងគេ, Anu ទេពគ្រាប់គ្រងឋានសួគ៌, Anunnaki ឬ Ea ជាទេពបង្កើតទឹក និងជាទេពដែលមានចំណេះដឹងផ្នែកមន្តអាគម, Ninhursag ជាទេពស្រី និងទេពនៃការផ្តល់កំណើត, Nanna អាទិទេពតំណាងឱ្យព្រះចន្ទ, Utu អាទិទេពតំណាងឱ្យព្រះអាទិត្យ យុតិធម៌ និង Inanna ជាអាទិទេពនៃសេចក្តីស្រលាញ់នយោបាយ និងសង្គ្រាម។[៩] សាសនា គឺជាផ្នែកមួយនៃការីកចម្រើននៃអរិយធម៌ ជាពិសេស សាសនា បានផ្សាភ្ជាប់ជាមួយនឹងសង្គម

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

---

[៣] *ibid*

[៤] Barbette Stanley Spaeth 2013:35

[៥] www.worldhsitory.org:Mesopotamia Religion

[៦] Jonh Baines , 1997:56

[៧] រូបស្តេច Hummrabi ចម្លាក់លើថ្មគោល

[៨] www.worldhsitory.org:Mesopotamia Religion

[៩] www.wikipidia.org: the seven gods of Mesopotamia

អត្ថបទដោយ៖ អេង តុលា

មនុស្សជាតិ ហើយអាទិទេពត្រូវបានគេចាត់ទុកថាជាអ្នកគ្រប់គ្រងកំពូលនៃច្បាប់គ្រប់គ្រង អាកាសធាតុ និងការបង្កកំណើតលើផែនដី[1]។



រូបលេខ១៖ គំនូរ3D នៃប្រាសាទ Ziggurat of Urakកសាងដល់អាទិទេព Anu

ប្រភព៖ Artefacts



រូបលេខ២៖ ចម្លាក់រូបអាទិទេពបរបាញ់ (Hunting god (full-Face)

ប្រភព៖ The British Museum

1 Barbette Stanley Spaeth 2013:44



រូបលេខ៣៖ ចម្លាក់ស្តេច Hammurabi ជាមួយនឹងអាទិទេព
ប្រភព៖ The British Museum



រូបលេខ៤៖ រូបចម្លាក់ Gudea
ប្រភព៖ Metmuseum.org

អត្ថបទដោយៈ អេង តុលា



រូបលេខ២៥៖ ចម្លាក់បង្ហាញពីអាទិទេព Anunnaki

ប្រភព៖ Printerest



រូបលេខ២៦៖ ចម្លាក់បង្ហាញពីអាទិទេព Anunnaki

ប្រភព៖ Printerest



រូបលេខ៧៖ ម្ចាស់ក្សត្រីពេលរាត្រី

(Queen of the night )

ប្រភព៖ British Museum



រូបលេខ៨៖ អាទិទេព Enil អង្គុយដែល

រកឃើញនៅNippur

ប្រភព៖ Iraq museum

អត្ថបទដោយ៖ អេង តុលា

# ឯកសារយោង

Dominique Charpin

2011 Histoire de la Mésopotamie

Benjamin R. Foster

2016 Mésopotamie : un monde religieux

Barbette Stanley Spaeth

2013 Ancient Mediterranean religions

Website Internet

www.history.com

www.histoire-du-monde.fr

www.britannica.com

www.worldhistory.org

www.wikipedia.rog

AMS
KHMER CIVILIZATION

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា